# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ១៨១៧,៨៥ ហិកតា មានទីតាំងនៅក្នុងឃុំសុចិត្រ និងឃុំទំរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីឈ្នួលនៅ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនិតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ផ្ទៃដីទំហំ ១៨១៧,៨៥ (មួយពាន់ប្រាំបីរយដប់ប្រាំពីរក្បៀសប៉ែតសិបប្រាំ) ហិកតា ស្ថិតនៅក្នុងឃុំសុចិត្រ និងឃុំទំរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM Zone 48 N, Indian 1960 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 555000 | 1428500 | 7 | 552500 | 1424000 |
| 2 | 555000 | 1428000 | 8 | 552500 | 1425000 |
| 3 | 556000 | 1428000 | 9 | 552081 | 1425000 |
| 4 | 556000 | 1424700 | 10 | 551000 | 1428500 |
| 5 | 555000 | 1424700 | 11 | 551000 | 1428000 |
| 6 | 555000 | 1424000 | | | |

**មាត្រា ២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះដែលជាដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ។

**មាត្រា ៣.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ២ ខាងលើ ជូនអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ និងធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដី និងខ្វះដី។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ០៤ ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាន គសសជ
-គ្រប់សមាជិក គសសជ
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ១៨១៧.៨៥ (មួយពាន់ប្រាំបីរយដប់ប្រាំពីរក្បៀសប៉ែតសិបប្រាំ) ហិកតា ស្ថិតនៅ ឃុំទំរីង និងឃុំសុចិត្រ ស្រុកសណ្តាន់ ខេត្តកំពង់ធំ**

**ឧបសម្ព័ន្ធអនុក្រឹត្យលេខ៖....៥៧៦.អនក្រ.បក..ចុះថ្ងៃទី..១៧..ខែ..មេសា..ឆ្នាំ២០១២**




| ID | X | Y |
|---|---|---|
| 1 | 555000 | 1428500 |
| 2 | 555000 | 1428000 |
| 3 | 556000 | 1428000 |
| 4 | 556000 | 1424700 |
| 5 | 555000 | 1424700 |
| 6 | 555000 | 1424000 |
| 7 | 552500 | 1424000 |
| 8 | 552500 | 1425000 |
| 9 | 552081 | 1425000 |
| 10 | 551000 | 1428500 |
| 11 | 551000 | 1428000 |

COORDINATESYSTEM
Projection UTM
ZON 48N
Datum Indian60
Spherold Everest

ទីតាំងសម្បទាន ដីសង្គមកិច្ច

2,000 1,000 0 2,000
Kilometers